**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ០៨ សរណន

# សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនិនាថ សីហនុ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា

ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃ អង្គារ ទី ១៨ ខែ មិថុនា ឆ្នាំ២០០២ ខាងមុខនេះ ។

-ដើម្បីសំដែងនូវភក្តីភាពប្រកបដោយកតញ្ញូតាធម៌ តបស្នងសងព្រះមហាករុណាធិគុណដ៏ធំធេងក្នុងមនោសញ្ចេតនាគោរពដឹងព្រះគុណដ៏ជ្រាលជ្រៅចំពោះសម្តេចម៉ែ ដែលព្រះអង្គបានលះបង់ព្រះកាយពលក្នុងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តម ដើម្បីបុព្វហេតុជាតិមាតុភូមិអង្គរជាទីស្នេហា និងប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គ ពិសេសលើវិស័យមនុស្សធម៌ សង្គមកិច្ច សុខមាលភាពទូទៅ ។ល។

-ដើម្បីចូលរួមអបអរសាទរ ថ្វាយព្រះពរសព្ទសាធុការ បវរមហាប្រសើរ ចំពោះសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ក្នុងឱកាសព្រះរាជពិធីបុណ្យចំរើនព្រះជន្មរបស់ព្រះអង្គ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំ ដូចតទៅនេះ :

១-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ សាលាខេត្ត-ក្រុង សាលារៀន រោងចក្រសហគ្រាស និងគ្រឹះស្ថាន ក្រុមហ៊ុនឯកជននានា ត្រូវរៀបចំតុបតែង បដា ពាក្យស្លោក តាំងព្រះឆាយាលក្ខណ៍សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនិនាថ សីហនុ** មានតាំងភ្លើងពណ៌ និងមានពាក្យស្លោក ថ្វាយព្រះពរ ។

២-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវធ្វើលិខិតថ្វាយព្រះពរសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានមុនថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០២ និងផ្ញើជូនបណ្តាញសារពត៌មាន វិទ្យុ និងទូរទស្សន៍ កាសែត ដើម្បីផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ។

៣-ក្រសួងព្រះបរមរាជវាំង និងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ឱ្យបានសមស្របទៅនឹងប្រពៃណីសាសនា និងប្រពៃណីជាតិ តាមការសព្វព្រះរាជហឫទ័យរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ។

៤-ក្រសួងព័ត៌មាន ត្រូវចាត់តាំងរៀបចំកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ជាតិ-ឯកជន អំពីព្រះរាជជីវប្រវត្តិ ព្រះរាជសកម្មភាព និងស្នាព្រះហស្តរបស់សម្តេច **ព្រះរាជអគ្គមហេសី** ជាទីសក្ការៈ ចំពោះប្រទេសជាតិ និងចំពោះ ប្រជារាស្ត្រ ឱ្យបានទូលំទូលាយ ។

៥-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្ត-ក្រុង ចាត់តាំងសំដែងសិល្បៈ ជូនមហាជនកំសាន្តសប្បាយទៅតាមទីធ្លាសាធារណៈ នៅថ្ងៃ អង្គារ ទី ១៨ ខែមិថុនា ឆ្នាំ ២០០២ តាមខ្លឹមសារ និងពេលវេលាសមស្រប ។

៦-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាព ក្រោមឱវាទ ខេត្ត-ក្រុង បង្កើនកិច្ចការពារ រក្សាសណ្តាប់ធ្នាប់សង្គម សុវត្ថិភាព សន្តិសុខ បង្កលក្ខណៈ ជូនប្រជាពលរដ្ឋកំសាន្តសប្បាយ អបអរសាទរក្នុងព្រះរាជពិធីបុណ្យនេះ ឱ្យបានឧឡារិកអធិកអធម សក្តិសមទៅនឹងព្រះកិត្តិនាម និងព្រះគុណូបការៈដ៏ធំធេងនៃសម្តេចម៉ែ ជាទីសក្ការៈ ។

ទទួលបានផែនការណែនាំនេះ ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តឱ្យទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន
និងគ្រប់ខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោក

---

- សូមថ្វាយព្រះពរសម្តេចម៉ែ ជាទីគោរពសក្ការៈ ក្នុងព្រះជន្មគំរប់ ៦៦ យាងចូល ៦៧ ព្រះវស្សា សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ
- សូមថ្វាយព្រះពរបវរមហាប្រសើរ សម្តេចឪ សម្តេចម៉ែ មានព្រះសុខភាពល្អ បរិបូរណ៍ និងព្រះជន្មាយុយឺនយូរ
- ជយោ ! ព្រះរាជាណាចក្រកម្ពុជា
- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍
- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ
- ជាតិ សាសនា ព្រះមហាក្សត្រ

❀❀❀